**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ: **១៦២០ អ.ក**
ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៣
សាលក្រមលេខ:៥២(ឃ)
ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជំនុំជម្រះជាសាធារណៈនាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ៨:៣០ នាទីព្រឹក ដោយមានសមាសភាពដូចតទៅ:

## ចៅក្រមជំនុំជម្រះ

| | | |
|---|---|---|
| លោក | [redacted] | ប្រធានក្រុមប្រឹក្សាចៅក្រមជំនុំជម្រះ |
| លោកស្រី | | ចៅក្រមក្រុមប្រឹក្សាជំនុំជម្រះ |
| លោក | | ចៅក្រមក្រុមប្រឹក្សាជំនុំជម្រះ |

## តំណាងអយ្យការ

| | | |
|---|---|---|
| លោកស្រី | [redacted] | ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល |

## ក្រឡាបញ្ជីសវនាការ

| | | |
|---|---|---|
| លោក | [redacted] | ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល |

## មេធាវី

| | | |
|---|---|---|
| លោក | [redacted] | មេធាវីការពារជនត្រូវចោទ |

## ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ:**១៦២០ អ.ក** ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៣ ដែលមាន៖

១-ជនជាប់ចោទ ឈ្មោះ: [redacted] **ភក្រា ហៅ ឡយ** ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ: [redacted] គុណ (រ) ម្ដាយឈ្មោះ: [redacted] ចាន់ថុល (រ) នៅលើវ កម្រិតវប្បធម៌ថ្នាក់ទី០៨ ទោសពីមុនគ្មាន ជាអនីតិជន។ **(ក្នុងឃុំ)**

២-ជនជាប់ចោទឈ្មោះ: [redacted] **សារិ** ហៅគ្រិ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ: [redacted] សំរិទ្ធ (រ) ម្ដាយឈ្មោះ: [redacted] សុធា (រ) នៅលើវ ជាអនីតិជន។(គេចខ្លួន)

ជាប់ចោទពីបទ៖ **អំពើលួច** ប្រព្រឹត្តនៅចំណុច ភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្ដាល កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសដែលមានចែងតាមបញ្ញត្តិ**មាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ** ។

-ដើមបណ្ដឹងឈ្មោះ: [redacted] **គន្ធា** ភេទប្រុស កើតឆ្នាំ១៩៣៩ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិវត្ត [redacted] ខេត្តកំពង់ស្ពឺ និងទីលំនៅបច្ចុប្បន្ននៅ ភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្ដាល ។

Scanned with CamScanner

## ការប្រព្រឹត្តរបស់ជនជាប់ចោទខាងលើមានដូចតទៅ ៖

កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង១៤ និង០០ នាទី មានជនរងគ្រោះឈ្មោះ [redacted] គន្ធា បានចូលទៅងូតទឹកនៅក្នុងបរិវេណវត្តផ្សារដែកលើ ស្ថិតក្នុងភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល ភ្លាមនោះក៏មានជនសង្ស័យចំនួន ០២នាក់ មានឈ្មោះ [redacted] ភក្រា និងឈ្មោះ [redacted] សារិ បាននាំគ្នា ចូលទៅធ្វើសកម្មភាពលួចលួចប្រាក់របស់ជនរងគ្រោះបានចំនួន ៤០០,០០០(សែសិបម៉ឺន)រៀល ។ លុះដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ០៩ព្រឹក ជនរងគ្រោះបានដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលផ្សារដែក ក្រោយពីទទួលបានពាក្យបណ្តឹងកម្លាំងសមត្ថកិច្ចបានចុះទៅធ្វើការឃាត់ខ្លួនជនសង្ស័យចំនួន០១នាក់ មានឈ្មោះ [redacted] ភក្រា រួមជាមួយវត្ថុតាង រួចបញ្ជូនមកអធិការដ្ឋាននគរបាលស្រុកពញាឮ ដើម្បីកសាងសំណុំរឿង និងចាត់ការតាមនីតិវិធីច្បាប់តែម្តង ។ កន្លងមកខ្លួនធ្លាប់ធ្វើសកម្មភាពលួចទ្រព្យសម្បត្តិរបស់ជនរងគ្រោះជាមួយ ឈ្មោះ [redacted] សារិ ចំនួន០៥ដង និងឈ្មោះ ហ៊ីង ចំនួន០១ដង ។

- បានឃើញ ដីកាបញ្ជូនសន្និដ្ឋានរឿងឲ្យស៊ើបសួរលេខ ១២៨៣ ដកសស ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៣ របស់តំណាងអយ្យការសាលាដំបូងខេត្តកណ្តាល ។
- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៣៤៦ ដកសព ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។
- បានឃើញ ដីកាដំណោះស្រាយលេខ ១៣៥៤ ដកដស ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ។
- បានឃើញ ដីកាចាត់តាំងប្រធានក្រុមប្រឹក្សាជំនុំជម្រះលេខ ១៥២៣ ដកចត ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តកណ្តាល ។

## នាពេលសវនាការ

១- តាមចម្លើយរបស់ជនជាប់ចោទថា ខ្លួនទទួលស្គាល់អង្គហេតុ សារិ រត់គេចខ្លួនបាត់ហើយ ខ្លួនធ្លាប់បានធ្វើសកម្មភាពលួចបានចំនួន០៥ដង ដោយ០៤ដងមុន ឡាយ សារិ ជាអ្នកលួច ហើយខ្លួនមើលផ្លូវ ។ ពួកខ្លួនលួចលុយនៅក្នុងវត្តជិតបន្ទប់ទឹក លុយនៅក្នុងហោប៉ៅរបស់តាអាចារ្យ ឃើញប៉ុណ្ណាយកទាំងអស់។ សមត្ថកិច្ចចាប់ខ្លួននៅតាមផ្លូវ(វត្តផ្សារដែកលើ) ។

២- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ជនជាប់ចោទទទួលស្គាល់កំហុស មានអង្គហេតុ និង ភស្តុតាងត្រឹមត្រូវដូច្នេះ តំណាងអយ្យការសូមតម្កល់ការចោទប្រកាន់ទុកជាបានការដដែល (ដូចមានបញ្ជាក់នៅក្នុងកំណត់ ហេតុសវនាការ) គប្បីតុលាការយកមកធ្វើការពិចារណា និងសម្រេចតាមការប្តឹងសុំរបស់តំណាងអយ្យការ ។

៣- មេធាវីបានធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីរបស់ខ្លួន គាត់បានទទួលស្គាល់កំហុសហើយ ដោយសារកូនក្តីរបស់ខ្លួនជាអនីតិជន ពុំទានមានស្មារតី និងគ្មានការមានការយល់ដឹង ព្រមទាំងមានវិចារណញ្ញាណពុំទាន់គ្រប់គ្រាន់ដែលអាចវិនិច្ឆ័យបានថា អំពើដែលខ្លួនប្រព្រឹត្តគឺជាអំពើល្អឬមិនល្អដែលសង្គមមិនទទួលស្គាល់ និងបានរៀនសូត្របានតិចតួចត្រឹមថ្នាក់ទី០៨ ហេតុដូចនេះ ស្នើសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង។

៤- ជនជាប់ចោទបានសំណូមពរ៖ សូមឲ្យតុលាការបន្ធូរបន្ថយទោសដល់រូបខ្លួនផងដើម្បីកែខ្លួនធ្វើជាមនុស្សល្អក្នុងសង្គម ។

-ក្រោយពីបានពិនិត្យឯកសារនានានៅក្នុងសំណុំរឿង

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹង

Scanned with CamScanner

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ
-ក្រោយពីបានពិនិត្យ និងពិចារណាតាមផ្លូវច្បាប់រួចរាល់ហើយ

**សាលាដំបូងខេត្តកណ្តាល**

**យល់ឃើញថា** :

១-យោងតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ភក្រា** ភេទប្រុស អាយុ១៧ឆ្នាំ និងឈ្មោះ [redacted] **សារិ** តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងតាមការពិនិត្យឯកសារ ព្រមទាំងភស្តុតាងនានាដែលមានក្នុងសំណុំរឿងឃើញថា អង្គហេតុដែលតំណាងអយ្យការធ្វើការចោទប្រកាន់មកលើ ជនជាប់ចោទខាងលើពីបទ **អំពើលួច** ប្រព្រឹត្តនៅ ក្នុងភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣ ប្រាកដមែន គប្បីតុលាការធ្វើការពិចារណាអំពីអង្គហេតុដែលចោទប្រកាន់។

២-ជនជាប់ចោទឈ្មោះ [redacted] **ភក្រា** ភេទប្រុស អាយុ១៧ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted] **សារិ** ភេទប្រុស អាយុ១៧ ជាអនីតិជន ជាជនជាប់ចោទពុំទាន់មានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនចំពោះមុខច្បាប់ទាំងស្រុងនោះឡើយ ប៉ុន្តែជនជាប់ចោទ មិនមានសញ្ញាណណាមួយ ដែលបង្ហាញថាជនជាប់ចោទមានសតិវិបល្លាសស្មារតីក្នុងពេលប្រព្រឹត្តបទល្មើសនោះឡើយ ដែលជាហេតុមិននាំឲ្យមានការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួនទេ។

៣-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ភក្រា ហៅ ឡយ** ភេទប្រុស អាយុ១៧ឆ្នាំ នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌, ដំណាក់កាលអយ្យការ, ដំណាក់កាលចៅក្រមស៊ើបសួរ បានឆ្លើយថា កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល២(ពីរ)រសៀល ខ្លួនកំពុងតែអង្គុយនៅផ្ទះស្រាប់តែឈ្មោះ [redacted] សារិ ហៅ គ្រី បានមកបបួលខ្លួនទៅលួចប្រាក់របស់តាអាចារ្យ នៅវត្តផ្សារដែកលើ បានចំនួន១០០(មួយរយ)ដុល្លាអាមេរិក រួចខ្លួនបានចែកគ្នាម្នាក់៥០(ហាសិប)ដុល្លាអាមេរិក លុះដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល១០ព្រឹក ស្រាប់តែមានសមត្ថកិច្ចចុះមកធ្វើការឃាត់ខ្លួនតែម្តង ។

៤-យោងទៅតាមចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] **គន្ធា** ដែលបានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល១២ថ្ងៃត្រង់ ខ្លួនបានចូលក្នុងបន្ទប់ទឹកដើម្បីងូតទឹក ហើយខ្លួនបានដោះអាវព្យួរលើជញ្ជាំងបន្ទប់ទឹក ស្រាប់តែមានក្មេងៗចំនួន០៣នាក់មានឈ្មោះ អាហេង ឈ្មោះ [redacted] ភក្រា ហៅអាឡយ និងឈ្មោះ គ្រី បានឆក់យកអាវរបស់ខ្លួនទៅបាត់ហើយនៅក្នុងអាវនោះមានប្រាក់ចំនួន៤២០០០០(សែសិបពីរម៉ឺន)រៀល ដែលខ្លួនទុកប្រើចំបាច់ក្នុងជីវភាពប្រចាំថ្ងៃ។ លុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣ ខ្លួនបានទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលផ្សារដែកតែម្តង ។

៥-យោងទៅតាមចម្លើយរបស់សាក្សីឈ្មោះ [redacted] **សុចហេង** ដែលបានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា នៅថ្ងៃកើតហេតុខ្លួនពុំបានដឹងអ្វីទេ លុះស្អែកឡើងទើបខ្លួនបានសុំឪពុកទៅលេងនៅវត្តផ្សារដែក ហើយក៏បានជួបជាមួយមិត្តភ័ក្រឈ្មោះ [redacted] ភក្រា ហៅឡយ ហើយបានមួយសន្ទុះក្រោយមកស្រាប់តែមានសមត្ថកិច្ចចុះមកឃាត់ខ្លួនឈ្មោះ [redacted] សុភ័ក្រ ហៅ ឡយ តែម្តង ។

Scanned with CamScanner

*បើយោងទៅតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ភក្រា ហៅ ឡុយ** ភេទប្រុស អាយុ១៧ឆ្នាំ និងដើមបណ្តឹងឈ្មោះ [redacted] **តន្លា** ភេទប្រុស កើតឆ្នាំ១៩៣៩ ដែលបានបំភ្លឺនៅមន្ត្រីនគរបាលយុត្តធម៌, ដំណាក់កាលអយ្យការ, ដំណាក់កាលចៅក្រមស៊ើបសួរ នាពេលសវនាការ និងឯកសារផ្សេងៗទៀតដែលមាននៅក្នុងសំណុំរឿង ព្រមទាំងកំណត់ហេតុដកហូតវត្ថុតាង អាចបញ្ជាក់ថាជនជាប់ចោទបានទទួលស្គាល់អង្គហេតុនិងបានឆ្លើយថាពិតជាបានលួចលុយដូចការចោទប្រកាន់ពិតប្រាកដមែន និងបានសារភាពថា ខ្លួនធ្លាប់បានធ្វើសកម្មភាពលួចជាមួយ [redacted] សារិ បានចំនួនសរុប០៥ដងមកហើយ ដោយឈ្មោះ សារិ ជាអ្នកចូលទៅលួចហើយខ្លួននៅចាំផ្លូវ ត្រង់ចំណុចនេះអាចឲ្យតុលាការជឿបានថា ជនជាប់ចោទគឺពិតជាបានប្រព្រឹត្តអំពើ **អំពើលួច** ។*

៦-ទំនាក់ទំនងហេតុបច្ច័យនៃទង្វើរបស់ជនជាប់ចោទឈ្មោះ [redacted] **ភក្រា** ភេទប្រុស អាយុ១៧ឆ្នាំ និងឈ្មោះ [redacted] **សារិ** ភេទប្រុស អាយុ១៧ឆ្នាំ ដែលបានប្រព្រឹត្តខុសពីច្បាប់របស់សង្គម ប៉ះពាល់របៀបរៀបរយ និងសណ្តាប់ធ្នាប់សារធារណៈ ពោលគឺជនជាប់ចោទឈ្មោះ [redacted] ភក្រា និងឈ្មោះ [redacted] សារិ បានធ្វើសកម្មភាពបបួលគ្នាទៅលួចលុយរបស់តាអាចារ្យនៅវត្តផ្សារដែកលើ ដោយលួចបានចំនួន៤០០០០០(សែសិបម៉ឺន)រៀល ហើយចែកគ្នាម្នាក់ពាក់កណ្តាល។

៧-ធាតុអត្តនោម័តរបស់ជនជាប់ចោទឈ្មោះ [redacted] **ភក្រា** ភេទប្រុស អាយុ១៧ឆ្នាំ និងឈ្មោះ [redacted] **សារិ** ភេទប្រុស អាយុ១៧ឆ្នាំ គឺជាអនីតិជន ដែលពុំទាន់មានស្មារតី ការយល់ដឹង ព្រមទាំងគ្មានវិចារណញ្ញាណគ្រប់គ្រាន់ដែលអាចវិនិច្ឆ័យបានថា អំពើដែលខ្លួនប្រព្រឹត្តគឺជាអំពើមិនល្អដែលសង្គមមិនទទួលស្គាល់ ហើយល្មើសទៅនឹងច្បាប់របស់ប្រទេសថែមទៀតផង។ ទោះបីជាដឹងយ៉ាងនេះក៏ដោយ ក៏ជនជាប់ចោទនៅតែមានឆន្ទៈ ក្នុងការប្រព្រឹត្តបទល្មើសដែលច្បាប់បានហាមឃាត់ដដែល ពោលគឺជនជាប់ចោទមានចេតនាយ៉ាងពិតប្រាកដក្នុងការប្រព្រឹត្តបទល្មើស ព្រោះជនជាប់ចោទឈ្មោះ [redacted] **សារិ** និងឈ្មោះ [redacted] **ភក្រា** មានចេតនាយ៉ាងពិតប្រាកដដោយបានធ្វើសកម្មភាពបបួលគ្នាទៅលួចលុយរបស់តាអាចារ្យ បានចំនួន៤០០០០០(សែសិបម៉ឺន)រៀល ដែលច្បាប់ចាត់ទុកអំពើនេះថាជាបទល្មើស **អំពើលួច** ប្រព្រឹត្តនៅភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសដែលមានចែងតាមបញ្ញត្តិ**មាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ** ។

៨-អំពើរបស់ជនជាប់ចោទឈ្មោះ[redacted] **ភក្រា** ភេទប្រុស អាយុ១៧ឆ្នាំ និងឈ្មោះ [redacted] **សារិ** ភេទប្រុស អាយុ១៧ឆ្នាំ ជាអំពើមួយដែលធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គម ប៉ះពាល់ដល់ សន្តិសុខសង្គម ជាអំពើមួយដែលច្បាប់បញ្ញត្តិចែងថាជា ៖ **អំពើលួច** ប្រព្រឹត្តនៅភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសដែលមានចែងតាមបញ្ញត្តិ**មាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ**។ គប្បីតុលាការសម្រេចធ្វើការប្រកាសទោសឲ្យជនជាប់ចោទទទួលខុសត្រូវតាមបញ្ញត្តិមាត្រាខាងលើ។

៩- មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសទៅលើជនជាប់ចោទឈ្មោះ [redacted] **ភក្រា** ភេទប្រុស អាយុ១៧ឆ្នាំ និងឈ្មោះ [redacted] **សារិ** ភេទប្រុស អាយុ១៧ឆ្នាំ ពីបទ **អំពើលួច** ប្រព្រឹត្តនៅភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសដែលមានចែងតាមបញ្ញត្តិ**មាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ** ។

Scanned with CamScanner

១០-**វត្ថុចាប់យករួមមាន៖** អាវក្រណាត់ដៃវែង(អាវអាចារ្យ) ចំនួន០១ពណ៌ស កម្មុលមានហោប៉ៅអាវចំនួន ០៣ លើ១ក្រោម២ មានឡេវចំនួន០៤(របស់ជនរងគ្រោះ) ។

## វិនិច្ឆ័យសេចក្ដី

ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **ភក្រា ហៅ ឡុយ** ភេទប្រុស អាយុ១៧ ឆ្នាំ និងឈ្មោះ [redacted] **សារិ** ភេទប្រុស អាយុ១៧ឆ្នាំ មានអត្តសញ្ញាណដូចខាងលើ ដាក់ពន្ធនាគារកំណត់ រយៈពេលចំនួន **១០(ដប់)ខែ** ពីបទ៖ **អំពើលួច** ប្រព្រឹត្តនៅភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្ដាល កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសដែលមានចែងតាមបញ្ញត្តិ**មាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ** ។

សាលក្រមនេះជំនុំជំរះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ភក្រា ហៅ ឡុយ** កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **សារិ ហៅគ្រិ** កំបាំងមុខដើមបណ្ដឹងឈ្មោះ [redacted] **គន្ធា** ។

**- ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។**

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១០រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កណ្ដាល, ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner